**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Sep-2012, 11:55
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឲ្យស្តាប់ការបន្ទាញតស្កូតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី គី តួន លើកទីពីរ ធ្វើឡើងដោយ ក.ស.ច.ស**

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រមJean-Marc LAVERGNE
ចៅក្រម **យូ ឧត្តរា**
**សហមេធាវីនាំមុខតំណាងដើម**

**ចម្លងជូន៖**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន
**មេធាវីការពារក្តី:**
សុន អរុណ
Michiel PESTMAN

ដើមបណ្តឹងរដ្ឋប្បវេណី៖
ពេជ អង្គ
Elisabeth SIMONNEAU FORT

Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវីការពាក្តី លោក អៀង សារី ("ក្រុមមេធាវីការពារក្តី") នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង កោះហៅ និងស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ដែលមានវត្តមាននៅពេលស្តាប់ចម្លើយសាក្សី រ៉ដាម តុន ហៅ ភី ភួន ដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេតការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ស.ច") លើកទីពីរ "សំណើ"[1]។

2. ញត្តិស្នើសុំរបស់មេធាវីការពារក្តីនេះ គួរបានបដិសេធចោលទាំងមូលខាងនីតិវិធី ព្រមទាំងខាងខ្លឹមសារ វិធានរបស់ អវតក បានចែងយ៉ាងច្បាស់ថា ការចោទប្រកាន់អំពីកំហុស ឬភាពមិនប្រក្រតីនៅក្នុងសកម្មភាពនៃការស៊ើបសួរគោងតែត្រូវបានលើកឡើង និងដោះស្រាយនៅក្នុងអម្លុងពេលនៃដំណាក់កាលមុនសវនាការ។ ផលប្រយោជន៍នៃភាពមានប្រសិទ្ធភាព និងភាពឆាប់រហ័សនៃសវនាការរបស់តុលាការនឹងត្រូវបានរាំងស្ទាត់មិនឲ្យធ្វើបានសម្រេចទេ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងត្រូវបង្ខំចិត្តឲ្យធ្វើការពិនិត្យមើលឡើងវិញជាទៀងទាត់ នូវបញ្ហានានាទាក់ទងនឹងនីតិវិធីដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដែលមេធាវីការពារក្តីត្រូវបានគេរំពឹងទុកថានឹងលើកឡើងជូនទៅអង្គបុរេជំនុំជម្រះ។ លើសពីនេះ បណ្តឹងរបស់មេធាវីការពារក្តី ស្តីពីការខកខានរបស់មន្ត្រីស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការថតនូវរាល់ការប្រាស្រ័យទាក់ទងទាំងអស់ជាមួយសាក្សីនានាត្រូវបានដាក់ខុសកន្លែង ដោយសារតែអង្គជំនុំជម្រះបានសម្រេចរួចពីមុនហើយថា វិធានរបស់ អវតក មិនបានតម្រូវឲ្យធ្វើការថតជាសោតទស្សន៍នូវការស្តាប់ចម្លើយសាក្សីឡើយ។

3. ជាសារធាតុ ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីត្រូវបានធានា ដោយសវនាការចំនួនប្រាំថ្ងៃនៃការផ្តល់សក្ខីកម្មសវនាការដោយសាក្សី រួមទាំងជាងពីរថ្ងៃនៃការសួរដេញដោលសាក្សីរបស់ភាគីម្ខាងទៀតដោយជនជាប់ចោទបីរូប។ សាក្សីបានបញ្ជាក់ម្តងហើយម្តងទៀតពីភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយរបស់ កសចស ទាំងនៅពេលដែលពួកគេបានធ្វើដំបូង និងទាំង

---

[1] ឯកសារ **E221** សំណើរបស់អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកជាការលេងល្បិចកែ្លក ថ្ងៃទី២៣ ខែ សីហា ឆ្នាំ ២០១២ (បន្ទាប់ពីនេះយោងដោយ "សំណើ")។

នៅពេល ដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយមេធាវីការពារក្តីមានឱកាសដ៏លើសលប់ក្នុងការសួរដេញដោលសាក្សីរបស់ភាគីម្ខាងទៀតនៅលើបញ្ហាបែបដូច្នោះ។ ក្នុងស្ថានការណ៍នេះ គឺវាគ្រាន់តែមិនមានមូលហេតុសម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្ម ពីអ្នកបកប្រែពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃកិច្ចដំណើរការនីតិវិធី នៃបទសម្ភាសន៍មួយដែលមានអាយុបួនឆ្នាំទៅហើយ។

4. សហព្រះរាជអាជ្ញាក៏បានសង្កេតឃើញដែរថា មេធាវីការពារក្តី បានរំលោភ ដែលគេបានស្គាល់ថាជា វិធានស្នូលមួយរបស់តុលាការនេះ ដោយធ្វើការពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយសាក្សីម្នាក់ដែលគេបានស្នើឡើង។ ក្នុងពេលជាមួយគ្នានេះ ដោយខ្លួនបានធ្វើការចោទប្រកាន់អំពី "ល្បិចស្ពិនភ្នែក" ប្រឆាំងនឹងអ្នកស៊ើបអង្កេតរបស់ កសចស នោះមេធាវីការពារក្តីបានរំលោភដោយឥតអៀនខ្មាស លើវិធានជាមូលដ្ឋានមួយដែលមានចេតនារារាំងគ្រប់ភាគីទាំងអស់ មិនឲ្យដាក់ឥទ្ធិពល ឬមិនឲ្យដាក់សម្ពាធលើសាក្សីសក្តានុពល។ ពួកគេមិនគួរទទួលបានការលើកទឹកចិត្តចំពោះការប្រព្រឹត្តិជាក់ស្តែងរបស់ខ្លួននេះឡើយ។

## II. **ឧទ្ធរណ៍**

### ក. កំហុសនីតិវិធីដែលបានចោទប្រកាន់ក្នុងកិច្ចស៊ើបសួរ មិនអាចលើកឡើងក្នុងដំណាក់កាលជំនុំជម្រះក្តីបានទេ

5. សំណើនេះ ផ្អែកទាំងស្រុងលើកំហុសនីតិវិធីដែលបានចោទប្រកាន់ក្នុងកិច្ចស៊ើបសួរ ជាពិសេសនៅពេលស្តាប់ចម្លើយលើកទី២ របស់សាក្សី ភី ភួន ធ្វើឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា "វិធានផ្ទៃក្នុងមិនបានចែងអំពីការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង អំពីភាពត្រឹមត្រូវនៃនីតិវិធីនៃការស៊ើបសួរ នៅពេលទទួលបានសំណុំរឿងនេះទេ[2]"។

6. អនុលោមតាមវិធានទាំងនោះ បណ្តឹងសុំមោឃភាពទាក់ទងនឹងកំហុសនីតិវិធី អាចដាក់បាន តែនៅមុនដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ។ ក្នុងអំឡុងពេលកិច្ចស៊ើបសួរ អនុលោមតាមវិធាន៧៦ ជន

---

[2] ឯកសារ**E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៧ (បន្ទាប់ពីនេះយោងដោយ "សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ")។

ជាប់ចោទមានសិទ្ធិដាក់បណ្តឹងសុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយ ឬកិច្ចស៊ើបសួរនានា។ វិធាន ៧៤ (ខ) ចែងថា "មានតែ" អង្គបុរេជំនុំជម្រះ "មានសមត្ថកិច្ច" ដើម្បីពិនិត្យមើលបណ្តឹងបែបនេះ។ វិធាន៧៦ (៧) ចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនីតិវិធីក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"[3]។ អាស្រ័យហេតុនេះ វិធាន អ.វ.ត.ក បញ្ជាក់យ៉ាងច្បាស់ថា ការជំទាស់ទៅនឹងដំណើរការនីតិវិធីក្នុងការស៊ើបសួរ ត្រូវបានកំណត់ធ្វើឲ្យបានមុនដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ។

7. សំណើរបស់មេធាវីការពារក្តី រំលោភលើការបែងចែកសមត្ថកិច្ច ដែលបានចែងក្នុងវិធានទាំងពីរខាងលើ និងរចនាសម្ព័ន្ធទូទៅនៃ អ.វ.ត.ក រវាងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូង "មិនមែនជាសាលាឧទ្ធរណ៍ ហើយក៏មិនមែនជាស្ថាប័នដែលត្រូវត្រួតពិនិត្យឡើងវិញ ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះទេ"[4]។ អាស្រ័យហេតុនេះ "ជាទូទៅ នៅក្នុងដំណាក់កាលស៊ើបសួរ ការជំទាស់ទៅនឹងដំណើរការនីតិវិធី ឬសេចក្តីសម្រេចនានា ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវតែលើកឡើងដោយអង្គដែលមានសមត្ថកិច្ចរបស់តុលាការ មុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ"[5] តែប៉ុណ្ណោះ។

8. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា មានការលើកលែងចំពោះវិធាន ៧៦ (៧) "ក្នុងករណីភាគីអាចបង្ហាញថា ពួកគេមិនមានឱកាសរកឲ្យឃើញនូវការបំភ្លៃង ដែលត្រូវបានចោទប្រកាន់ នៅមុនពេលបើកសវនាការលើអង្គសេចក្តី ឬក្នុងករណីមានភាពចាំបាច់ ដើម្បីគាំពារភាពយុត្តិធម៌នៃកិច្ចដំណើការនីតិវិធីជំនុំជម្រះក្តី"[6]។ ក្នុងករណីនេះ មិនមែនការលើកលែងដូច

---

[3] *សូមមើលផងដែរ* ឯកសារ E71/1 សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២។

[4] ឯកសារ E116 សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។

[5] *សូមមើលផងដែរ* ឯកសារ E116 សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ ១៥។

[6] ឯកសារ E142/3 សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ នួន ជា ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយ

លើកឡើងខាងលើទេ ដោយហេតុថា ក្រុមមេធាវីការពារក្ដីមានពេលវេលាគ្រប់គ្រាន់ ដើម្បីរកឲ្យឃើញនូវបញ្ហាដែលខ្លួនលើកឡើងក្នុងសំណើដែលបង្ហាញដោយ "សមាជិកក្រុមដែលនិយាយភាសាខ្មែរនៃ [ក្រុមមេធាវីការពារក្ដី]...ពិនិត្យមើលឡើងវិញនូវខ្សែអាត់ថតសំឡេងនៃការស្ដាប់ចម្លើយ ភី ភួន"[7] របស់ កសចស។ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការកត់សម្គាល់ហើយថា៖

> *ខ្សែអាត់សំឡេង និងកំណត់ហេតុស្ដាប់ចម្លើយ ត្រូវបានដាក់ចូលក្នុងសំណុំរឿងជាបន្តបន្ទាប់ ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ហើយដូច្នេះ ភាគីមានលទ្ធភាពពិនិត្យមើលឯកសារទាំងនោះបាន (ទាំងអ្នកចេះភាសាខ្មែរ ភាសាអង់គ្លេស និង/ឬភាសាបារាំង) ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ*[8] ។

9. ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់ក្រុមមេធាវីការពារក្ដី នួន ជា អំពីភាពមិនស៊ីសង្វាក់គ្នាដែលត្រូវបានចោទ រវាងខ្សែអាត់សំឡេង និងកំណត់ហេតុស្ដាប់ចម្លើយរបស់ ក.ស.ច.ស ដោយសម្រេចថា "ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលឯកសារក្នុងសំណុំរឿង ក្នុងនោះខ្សែអាត់សំឡេងផងដែរ" និងបានលើកឡើងថា ក្រុមមេធាវីការពារក្ដីខកខានមិនបានបង្ហាញថា ខ្លួនមិនអាចវាយតម្លៃអត្ថិភាពនៃភាពមិនប្រក្រតីដែលមានក្នុងកំណត់ហេតុស្ដាប់ចម្លើយ "មុនពេលបើកសវនាការឡើយ"[9]។ ស្រដៀងគ្នានេះដែរ ក្រុមមេធាវីការពារក្ដីអាចមានលទ្ធភាពពិនិត្យមើលឡើងវិញ ក្នុងអំឡុងពេលស៊ើបសួរ នូវខ្សែអាត់សំឡេង និងកំណត់ហេតុស្ដាប់ចម្លើយ ភី ភួន ជាសាក្សីសំខាន់មួយរូបដែលបានធ្វើការនៅក្នុងក្រសួងការបរទេស ច្បាស់ចំពោះ អៀង សារី ។ ហេតុដូច្នេះ វាមិនមានហេតុផលសមស្រប ចំពោះការខកខានមិនបានរកឃើញ ឬមិនបានលើកឡើងនូវបញ្ហាទាក់ទងនឹងកិច្ចដំណើរការនីតិវិធី មុនពេលបើកសវនការឡើយ។

---

សាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៧ (បន្ទាប់ពីនេះយោងដោយ "សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី"។

[7] ឯកសារ **E221** សំណើ កថាខណ្ឌ ២។

[8] ឯកសារ **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី កថាខណ្ឌ ៦, ៨។

[9] ឯកសារ **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី កថាខណ្ឌ៨។

### ខ. សក្ខីកម្មរបស់សាក្សីរូបនេះក្នុងពេលសវនាការ កែតម្រូវកំហុសនីតិវិធីក្នុងកំណត់ហេតុស្តាប់ចម្លើយ ក.ស.ច.ស របស់គាត់ និងការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ

10. លើសពីនេះ ការលើកលែងចំពោះវិធាន ៧៦ (៧) មិនមានភាពចាំបាច់ក្នុងការការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីឡើយ។ ទោះជាមានកំហុសនីតិវិធីក្នុងពេលស្តាប់ចម្លើយ ភី ភួន លើកទីពីរក៏ដោយ ក៏សាក្សីបានផ្តល់សក្ខីកម្មក្នុងតុលាការ ហើយក្រុមមេធាវីការពារក្តីមានឱកាសសាកសួរដេញដោលអំពីខ្លឹមសារនៃសក្ខីកម្មរបស់គាត់ និងកិច្ចដំណើរការនីតិវិធី ក្នុងអំឡុងពេលស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស ផងដែរ។ អាស្រ័យហេតុនេះ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីរូបនេះ សិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌របស់ជនជាប់ចោទ ត្រូវបានការពារគ្រប់គ្រាន់ហើយ។

11. ក្នុងការច្រានចោលសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ផ្អែកលើវិធាន ៣៥ អំពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់រវាងកំណត់ត្រាស្តាប់ចម្លើយ និងខ្សែអាត់សំឡេង អង្គជំនុំជម្រះសម្រេចថា "ទោះក្រោមកាលៈទេសៈបែបណាក្តី ក៏ក្រុមមេធាវីការពារក្តីនឹងទទួលបានការគាំពារថែមទៀតនូវលទ្ធភាពក្នុងការសួរសំណួរទៅសាក្សីទាំងឡាយ នៅសវនាការស្តីពីចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ នៅពេលដែលចំណុចមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់ទាំងអស់នេះ ពាក់ព័ន្ធជាក់ស្តែងទៅនឹងការវាយតម្លៃភ័ស្តុតាងភរនីភាព ឬចាំបាច់សម្រាប់ការការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីសវនាការ"[10]។ ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តីដទៃទៀត ត្រូវបានអនុញ្ញាតឲ្យសួរដេញដោល ភី ភួន រយៈពេល ២ និង១/៤ ថ្ងៃ (ចាប់ពីថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២)។ ដូច្នេះនៅពេលនេះ ក្រុមមេធាវីការពារក្តីមិនអាចអះអាងគួរឲ្យជឿជាក់បានថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺមិនត្រូវបានការពារគ្រប់គ្រាន់ទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះឡើយ។

12. សូមបញ្ជាក់ផងដែរថា ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានស្នើឲ្យផ្អែកទាំងស្រុងលើកំណត់ហេតុស្តាប់ចម្លើយរបស់ កសចស តែមួយប៉ុណ្ណោះទេ។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តី អៀង សារី លើកឡើងបញ្ហាមិនត្រឹមត្រូវ ដោយអះអាងថា វាមានភាពចាំបាច់

[10] ឯកសារ **E142/3** សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សី កថាខណ្ឌ ១៤។ *សូមមើលផងដែរ* **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ កថាខណ្ឌ១៩។

ក្នុងការស្តាប់សក្ខីកម្មអ្នកបកប្រែផ្ទាល់របស់ ក.ស.ច.ស ដើម្បីកំណត់អំពីភាពអាចទុកចិត្តបាន ឬ "តម្លៃនៃការថ្លឹងថ្លែង ប្រសិនបើមាន ដែលអាចផ្តល់ចម្លើយដែលមាននៅក្នុងការស្តាប់ចម្លើយ ភី ភួន លើកទីពីរ"[11]។ ដោយហេតុថា សាក្សី ភី ភួន ទទួលបានរយៈពេល៥ថ្ងៃ ក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចំណុចខ្វះចន្លោះដែលត្រូវបានចោទប្រកាន់ ក្នុងពេលស្តាប់ចម្លើយលើកទីពីរ ដែលបានធ្វើឡើងដោយ ស.ច.ក.ស មានផលវិបាកតូចតាចបំផុតប៉ុណ្ណោះ ឬមិនមានផលវិបាកអ្វីឡើយ។ ភស្តុតាងបឋមរបស់គាត់ត្រូវបានបង្ហាញរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរយៈពេល៥ថ្ងៃ ក្នុងតុលាការ។ ហេតុដូច្នេះ វាមិនចាំបាច់ដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវកោះអញ្ជើញអ្នកបកប្រែមួយរូប ឲ្យមកផ្តល់សក្ខីកម្ម ពាក់ព័ន្ធការស្តាប់ចម្លើយដែលបានធ្វើនៅខាងក្រៅតុលាការកាលពីបួនឆ្នាំមុន ដែលបានជំនួសរួចហើយ តាមរយៈសក្ខីកម្មក្នុងពេលសវនាការនោះទេ។

13. ផ្ទុយពីទឡ្ហីករណ៍របស់មេធាវីការពារក្តី សក្ខីកម្មដែលបានផ្តល់ដោយ ភី ភួន នៅពេលជំនុំជម្រះមានភាពច្បាស់លាស់ អាចជឿជាក់បាន និងស្របជាមួយចម្លើយរបស់គាត់ទាំងពីរលើកដែលបានផ្តល់ដល់ ក.ស.ច.ស។ ឧទាហរណ៍ មេធាវីការពារក្តីអះអាងថា មានភាពផ្ទុយគ្នារវាងចម្លើយលើកទី១ និងលើកទី២ របស់ ភី ភួន ដោយសារ ភី ភួន បានពិពណ៌នាការណ៍ដែល អៀង សារី បានទទួលចម្លើយសារភាព តែនៅពេលស្តាប់ចម្លើយលើកទី២ប៉ុណ្ណោះ[12]។ ការពិតពុំមានសញ្ញាណណាមួយបង្ហាញទាល់តែសោះដែលថា សាក្សីរូបនេះត្រូវបានសាកសួរទាក់ទិននឹងចម្លើយសារភាពនៅក្នុងការស្តាប់ចម្លើយលើកទី១ ជាមួយ ក.ស.ច.ស នោះទេ[13]។ នៅពេលសវនាការ សាក្សីរូបនេះបានបញ្ជាក់យ៉ាងច្បាស់ថា អៀង សារី ខ្លួនឯងបានប្រាប់គាត់អំពីការទទួលចម្លើយសារភាព[14]។ សក្ខីកម្មនេះស្របគ្នាទៅនឹងភស្តុតាងជាឯកសារ ដែលនៅក្នុង

---

[11] ឯកសារ **E221** សំណើ កថាខណ្ឌ ១៧។

[12] ឯកសារ **E221** សំណើ កថាខណ្ឌ១៦។

[13] ជាងនេះទៀត ផ្ទុយពីការកំណត់លក្ខណៈសម្បត្តិរបស់មេធាវីការពារក្តី សាក្សីរូបនេះបានរំឭកឡើងវិញនៅក្នុងការស្តាប់ចម្លើយលើកទី១ របស់គាត់ជាមួយ ក.ស.ច.ស ដែលនិយាយថា អៀង សារី បានពន្យល់ប្រាប់គាត់ថា មូលហេតុដែល កុយ ធួន ត្រូវបានគេចាប់ខ្លួននោះគឺដោយសារតែខុសសីលធម៌ផ្លូវភេទ។ ឯកសារ **E3/24** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រង់ ENG 00223585, FRE 00503926, KHM 00204072។

[14] ឯកសារ **E1/98.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ត្រង់ ENG 00831010-12 ("គាត់ប្រាប់ខ្ញុំថាមានចម្លើយដែលវាពាក់ព័ន្ធនឹង -- ខ្លះក៏ពាក់ព័ន្ធនឹងសេអ៊ីអា ខ្លះក៏ពាក់ព័ន្ធនឹងកាហ្សេបេ ខ្លះក៏ពាក់ព័ន្ធនឹងអាខ្មាំងយួនឈ្លានពាន អ៊ីចឹងទៅ")។

ចម្លើយសារភាពពីមន្ទីរ ស-២១ មានចំណារឈ្មោះ អៀង សារី[15] ស្របគ្នាទៅនឹងសក្ខីកម្មរបស់ប្រធានមន្ទីរ ស-២១ កាំង ហ្គេកអ៊ាវ ដែលថា ចម្លើយសារភាពដែលពាក់ព័ន្ធត្រូវបញ្ជូនទៅប្រធានស្ថាប័ននីមួយៗ របស់កម្ពុជាប្រជាធិបតេយ្យ[16] និងស្របគ្នាទៅនឹងសក្ខីកម្មរបស់សាក្សីសំខាន់ៗមួយចំនួនដែលមកពីក្រសួងការបរទេស ("MFA") ដែលបានបញ្ជាក់ថា អៀង សារី បានដឹង និងបានទទួលចម្លើយសារភាពទាំងនោះ[17]។ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តីផងដែរដែលថា សាក្សីរូបនេះបានលាក់បាំងពីការចូលរួមរបស់ខ្លួននៅក្នុងបញ្ហាសន្តិសុខ ភី ភួន បានទទួលស្គាល់តួនាទីរបស់គាត់ក្នុងការចាប់ខ្លួនកម្មាភិបាលនៅក្រសួងការបរទេស នៅពេលសាក្សីរូបនេះត្រូវបានសាកសួរជាលើកដំបូងអំពីប្រធានបទនេះ នៅពេលជំនុំជម្រះក្តី[18]។

14. ហេតុនេះ បន្ទាប់ពីគាត់បានផ្តល់សក្ខីកម្មយ៉ាងពិស្តារនៅពេលជំនុំជម្រះក្តីហើយនោះ ការពិតដែលមិនអាចប្រកែកបានគឺថា សាក្សីរូបនេះបាននិយាយយ៉ាងស្មោះត្រង់ពីអ្វីដែលគាត់បានដឹងទាំងនៅពេលជំនុំជម្រះក្តី ក៏ដូចជាក្នុងចម្លើយរបស់គាត់ដែលបានផ្តល់ដល់ ក.ស.ច.ស។ ពុំមានមូលហេតុណាមួយដែលត្រូវរៀបចំសវនាការ នៅក្នុងសវនាការ ដើម្បីសម្រេចពីកាលៈទេសៈនៃចម្លើយលើកទី២ របស់គាត់ដែលបានផ្តល់ដល់ ក.ស.ច.ស នោះឡើយ។

---

[15] ឯកសារ **D43/IV-Annex 41** ចម្លើយសារភាពមន្ទីរ ស២១ របស់ឈ្មោះ មាក ទូច ត្រង់ KHM 00174100, ENG 00771346; ឯកសារ **D43/IV-Annex 47** ចម្លើយសារភាព សាន ប៉ូ ត្រង់ KHM 00174132, ENG 00767463; ឯកសារ **E1/56.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ត្រង់ ENG 00796924-26, 00796957។

[16] ឯកសារ **E1/56.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ត្រង់ ENG 00796948-53។

[17] ឯកសារ **E1/67.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ ត្រង់ ENG 00804051-52 (សូ ហុង)។ ឯកសារ **E1/102.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១២ ត្រង់ ENG 00833279-81, 00833289-90 (ស្ួង ស៊ីគឿន)។ ឯកសារ **E1/105.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២ ត្រង់ ENG 00835375-76 (អ៊ុង ចុងហឿង)។

[18] ឯកសារ **E1/98.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០១២ ត្រង់ ENG 00831013-15។

**គ. កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ ក.ស.ច.ស បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវសេចក្ដីកម្មរបស់សាក្សី និងអនុលោមតាមវិធានរបស់ អ.វ.ត.ក**

15. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើការកត់សម្គាល់រួចមកហើយគឺថា "អនុលោមតាមទម្លាប់អនុវត្តទូទៅនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការស្ដាប់យកចម្លើយចំពោះមុខ ក.ស.ច.ស ពុំមែនជាកំណត់ហេតុឥតលម្អៀងឡើយ ប៉ុន្តែវាជារបាយការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានរៀបចំស្ដីពីចម្លើយពាក់ព័ន្ធរបស់សាក្សី ដើម្បីបណ្ដឹងរដ្ឋប្បវេណី ឬជនជាប់ចោទ"[19]។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានផងដែរថា វិធានផ្ទៃក្នុងនៃ អ.វ.ត.ក មិនបានកំណត់ថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវកត់ត្រាពីរវេលាពិតប្រាកដនៃការស្ដាប់ចម្លើយសាក្សី ឬការឈប់សម្រាកចន្លោះពេលស្ដាប់ចម្លើយនីមួយៗ ឬតម្រូវឲ្យថតសំឡេង ឬថតវីដេអូ ពីការស្ដាប់យកចម្លើយសាក្សីនោះទេ[20]។

16. អាស្រ័យហេតុនេះ បណ្ដឹងរបស់មេធាវីការពារក្ដី ពាក់ព័ន្ធនឹង (ក) អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានកត់ត្រាឲ្យបានច្បាស់ពីថិរវេលានៃការស្ដាប់យកចម្លើយ (ខ) អ្នកស៊ើបអង្កេតមិនបានកត់ត្រាពីការប្រាស្រ័យទាក់ទងនានាជាមួយសាក្សីម្នាក់ៗ និង (គ) អត្ថិភាពនៃចម្លើយជាលាយលក្ខណ៍អក្សរចំនួន ១២ ដែលមានក្នុងសំណុំរឿងដែលមិនបានថតសំឡេង[21] ពុំមែនជាការរំលោភទៅលើនីតិវិធីនៃវិធាន អ.វ.ត.ក ដែលធានាឲ្យអង្គជំនុំជម្រះត្រូវចាត់វិធានការនោះទេ។ ទោះបីអ្នកស៊ើបអង្កេតពុំតម្រូវឲ្យធ្វើបែបនេះក្ដី តែការស្ដាប់ចម្លើយភាគច្រើនរបស់ ក.ស.ច.ស ត្រូវបានធ្វើឡើងដោយថតសំឡេង ហើយខ្សែអាត់សំឡេងទាំងនោះត្រូវបានដាក់ក្នុងសំណុំរឿង ហើយមេធាវីការពារក្ដី និងភាគីដទៃទៀត ក៏អាចយកមកពិនិត្យបានដែរ។ ដូចដែលអង្គជំនុំជម្រះបានកត់សម្គាល់រួចមកហើយ គឺថាទម្លាប់អនុវត្តរបស់ ក.ស.ច.ស បែបនេះគឺ "មិនដូចទៅនឹងការបង្អាក់កិច្ចស៊ើបសួរដោយចេតនាឡើយ"[22]។

---

[19] ឯកសារ **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី កថាខណ្ឌ ១១។

[20] ឯកសារ **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី កថាខណ្ឌ៦ ជើងទំព័រ ១៣។

[21] ឯកសារ **E221** សំណើ កថាខណ្ឌ ៦, ១៥, ១៨ និង ជើងទំព័រ ៥២។

[22] ឯកសារ **E142/3** សេចក្ដីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សី កថាខណ្ឌ ១៤។

17. សហព្រះរាជអាជ្ញាក៏បានសង្កេតបន្ថែមទៀតថា ដោយមិនពិចារណាដល់ថា តើការស្តាប់យកចម្លើយរបស់ ភី ភួន លើកទី២ គឺពឹងផ្អែកលើ "ការស្តាប់យកចម្លើយដែលពុំបានថតសំឡេងជាមុន" ឬយ៉ាងណា ដូចដែលមេធាវីការពារក្តីបានចោទប្រកាន់នោះ[23] កំណត់ហេតុលាយលក្ខណ៍អក្សរនេះ ពិតជាបានសង្ខេបយ៉ាងត្រឹមត្រូវ និងសុក្រឹត្យអំពីការដឹង និងសក្ខីកម្មរបស់សាក្សី។ ភី ភួន បានបញ្ជាក់ពីភាពសុក្រឹត្យនៃចម្លើយនោះ ទាំងនៅពេលគាត់បានផ្តល់នាពេលនោះ (ដោយមានចុះហត្ថលេខា និងផ្តិតមេដៃនៅក្នុងកំណត់ហេតុ) <u>និងទាំង</u>ពេលគាត់មកផ្តល់សក្ខីកម្មក្នុងតុលាការ។ ហេតុនេះ ពុំមានមូលដ្ឋានណាមួយ ដើម្បីឲ្យមេធាវីការពារក្តីជំទាស់ថា កំណត់ហេតុលាយលក្ខណ៍អក្សរនោះ មិន"ឆ្លុះបញ្ចាំងសុក្រឹត្យ" ពីកំណត់ហេតុស្តាប់ចម្លើយលើកមុន ដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នោះទេ។ ពុំមានសញ្ញាណបង្ហាញថា សាក្សីរូបនេះត្រូវបានទទួលការណែនាំ ផ្តល់ព័ត៌មាន ឬជំរុញឲ្យផ្តល់សក្ខីកម្មមិនពិតនោះទេ។ សង្ខេបមក ការចោទប្រកាន់របស់មេធាវីការពារក្តីអំពីការក្លែងបន្លំ និង "និងការលេងផ្តិនផ្អែក" ជាការចោទប្រកាន់គ្មានមូលដ្ឋានសម្អាងទាល់តែសោះ។

18. ភាពមិនប្រក្រតីនៃនីតិវិធីដែលមេធាវីការពារក្តីបានចោទប្រកាន់ពុំបានបង្ហាញថា មានបញ្ហាខ្លឹមសារធ្ងន់ធ្ងរនៅក្នុងកំណត់ហេតុលាយលក្ខណ៍នៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ទេ។ ដូចដែលបានកត់សម្គាល់រួចមកហើយគឺថា ទម្លាប់អនុវត្តរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ខ្លះដែលបានពិភាក្សា ឬបានជួបជាមួយសាក្សី មុនពេលចាប់ផ្តើមការស្តាប់ចម្លើយផ្លូវការរបស់ខ្លួន មិនមែនជាការរំលោភដល់វិធាននៃ អ.វ.ត.ក ទេ ហើយវាទំនងជាការធានាដល់ការប្រាស្រ័យទាក់ទងបានល្អប្រសើរជាមួយសាក្សី និងធ្វើឲ្យកំណត់ហេតុជាលាយលក្ខណ៍អក្សរកាន់តែសុក្រឹត្យទៅទៀត។ ភាពខុសគ្នារវាងពេលចាប់ផ្តើម និងពេលបញ្ចប់នៅក្នុងកំណត់ជាលាយលក្ខណ៍អក្សរ និងរយៈពេលពិតប្រាកដនៃខ្សែអាត់សំឡេងត្រូវបានពន្យល់ដោយ (ក) ការឈប់សម្រាកក្នុងពេលស្តាប់ចម្លើយដែលខ្សែអាត់សំឡេងត្រូវផ្អាកសិន និង (ខ) តម្រូវការក្នុងការរៀបចំកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់អ្នកប្រតិចារឹកដែលត្រូវធ្វើនៅនឹងកន្លែង ដើម្បីរៀបចំឲ្យបានរួចរាល់ បោះពុម្ព ពិនិត្យឡើងវិញជាមួយសាក្សី និងចុះហត្ថលេខា មុនពេលការស្តាប់យកចម្លើយនោះត្រូវបានបញ្ចប់ជាផ្លូវការ។

---

[23] ឯកសារ **E221** សំណើ កថាខណ្ឌ ១៥។

19. សហព្រះរាជអាជ្ញាបានសង្កេតបន្តទៀតថា ទោះបីមានការប្រឹងប្រែងរួមគ្នារបស់ក្រុមមេធាវីការពារក្តីនៅពេលជំនុំជម្រះ ដើម្បីពិនិត្យ និងប្រៀបធៀបយ៉ាងយកចិត្តទុកដាក់នូវកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់យកចម្លើយនីមួយៗរបស់ ក.ស.ច.ស ទៅនឹងខ្សែអាត់សំឡេងនោះក៏ដោយ ក៏ភាពខ្វះចន្លោះដែលមេធាវីការពារក្តីបានរកឃើញគឺតិចតួច ហើយសាក្សីក៏បានបញ្ជាក់ម្តងហើយម្តងទៀត និងស្របគ្នាពីសុក្រឹតភាពនៃខ្លឹមសារ នៅក្នុងចម្លើយរបស់ខ្លួនដែរ។ ឧទាហរណ៍ ក្នុងអំឡុងពេលសាកសួរសាក្សីឈ្មោះ សៅ សារុន មេធាវីការពារក្តី ខៀវ សំផន មិនបានជំទាស់នឹងភាពសុក្រឹត្យទៅនឹងខ្លឹមសារនៃចម្លើយអំពីកូនក្តីរបស់ខ្លួន នៅក្នុងចម្លើយរបស់សាក្សីរូបនេះដែលបានផ្តល់ដល់ ក.ស.ច.ស ទេ តែផ្ទុយទៅនឹងមេធាវីការពារក្តីបែរជាតវ៉ាថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានបន្ថែមឈ្មោះហៅក្រៅរបស់ ខៀវ សំផន គឺ "ហែម" នៅពេលនិយាយដល់រូបគាត់ក្នុងកំណត់ហេតុលាយលក្ខណ៍អក្សរ[24]។ មេធាវីការពារក្តី នួន ជា សួរដេញដោលសាក្សី គឹម វុន ដែលផ្តោតលើមូលហេតុដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានបញ្ចូលព័ត៌មានដែលថា កូនក្តីរបស់ខ្លួនបានធ្វើបទបង្ហាញពីគោលនយោបាយផ្នែកកសិកម្មក្នុងអំឡុងពេលគាត់ឡើងកាន់អំណាចជំនួស យុន យាត នៅឯក្រសួងឃោសនាការ ទោះបីសាក្សីមិនដឹងច្បាស់ថា តើប្រធានបទនេះត្រូវបានយកមកពិចារណាក្នុងពេលស្តាប់យកចម្លើយរបស់គាត់ ឬយ៉ាងណានោះទេ[25]។ ការណ៍ដែលមេធាវីការពារក្តីប្រើការវាយប្រហារបែបតូចតាច និងមិនមានប្រយោជន៍ដដែលៗ ទៅលើកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស បែបនេះ គឺបានត្រឹមតែបញ្ជាក់ពីភាពជឿជាក់បានជាទូទៅ និងភាពសុក្រឹត្យនៃព័ត៌មានសំខាន់ៗដែលមានក្នុងចម្លើយទាំងនោះតែប៉ុណ្ណោះ។

---

[24] **E1/83.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១២ ត្រង់ ENG 00815607-09។

[25] **E1/113.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ត្រង់ ENG 00841889-93 ("**ស៖** តើលោកដឹងទេហេតុអ្វីបានជាលោកមិនបាននិយាយ និងឆ្លើយអំពីការអប់រំរបស់ នួន ជា ដែលផ្តោតសំខាន់ទៅលើកសិកម្មនោះដែលលោកជាចម្លើយមួយ លោកឆ្លើយទៅលោកចៅក្រមស៊ើបអង្កេតនោះ? **ឆ៖** ខ្ញុំមិនចាំ ប្រហែលជាខ្ញុំ គឺមិនបានសួរពីរឿងហ្នឹង ខ្ញុំអត់បានឆ្លើយ ... **ស៖** ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នា ដើម្បីចៀសវាងការយល់ច្រឡំទាំងអស់គ្នា។ តើលោកចាំដែរឬទេ ថាលោកបានលើកឡើងអំពីការអប់រំលើបញ្ហាកសិកម្មនេះ ដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតនោះ តើលោកចាំទេ លោកបានឆ្លើយដូច្នេះ? **ឆ៖** ខ្ញុំដូចភ្លេចភ្លាំង មិនដឹងសួរៗនៅពេលណា")។

## ឃ. មេធាវីការពារក្តីបានរំលោភដោយចេតនាលើវិធានផ្ទៃក្នុងរបស់តុលាការ ចំពោះការហាមឃាត់ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយភាគី និង សាក្សីដែលបានស្នើឡើង

20. ទាំងវិធានផ្ទៃក្នុង[26] និងទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[27] ផ្តល់អំណាចឱ្យសហចៅក្រមស៊ើបអង្កេត ("សចស") ដើម្បីដឹកនាំកិច្ចស៊ើបសួរ បន្ទាប់ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[28]។ ក្នុងអម្លុងពេលនៃដំណាក់កាលនៃកិច្ចស៊ើបសួរ ភាគីណាមួយដែលស្វែងរកព័ត៌មានផ្សេងៗ ត្រូវតែ "ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់កិច្ចស៊ើបសួរ"[29]។ សចស បានបញ្ជាក់អះអាងថា "អំណាចក្នុងការដឹកនាំកិច្ចស៊ើបសួរ ត្រូវបានចាត់តាំងឱ្យសហចៅក្រមស៊ើបអង្កេតឯករាជ្យតែពីររូបគត់ មិនមែនឱ្យភាគីឡើយ" និងថា "គ្មានបទប្បញ្ញត្តិណាផ្តល់សិទ្ធិអំណាចឱ្យភាគីបំពេញកិច្ចស៊ើបសួរឡើយ... ដែលអាចខុសពីករណីនៃប្រព័ន្ធនីតិវិធីផ្សេង"[30]។ នៅក្រោយការបញ្ចប់កិច្ចស៊ើបសួរ អំណាចដើម្បីដឹកនាំកិច្ចស៊ើបសួរបន្ថែម ប្រគល់ឱ្យអង្គជំនុំជម្រះសាលាដំបូង"[31]។ អង្គជំនុំជម្រះនេះក៏បានបញ្ជាក់

---

[26] សូមមើល វិធាន៥៥ (ដែលរៀបរាប់អំពីសិទ្ធិអំណាចក្នុងការស៊ើបសួររបស់ កសចស) និងវិធាន៦០(២) (ដែលចែងថា "សហចៅក្រមស៊ើបអង្កេតឬអ្នកទទួលសិទ្ធិ ត្រូវស្តាប់ចម្លើយសាក្សី ដោយគ្មានវត្តមានជនត្រូវចោទ ភាគីដទៃទៀត ឬមេធាវី")។

[27] មាត្រា២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា: "រាល់កិច្ចស៊ើបសួរ គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមនីតិវិធីដែលនៅជាធរមាន"។

[28] អនុលោមតាមវិធាន៥០ និង ៥៣, សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យដឹកនាំការស៊ើបអង្កេតបឋម ដែលត្រូវបញ្ចប់ដោយការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅ សចស។ *សូមអាន* ឯកសារ **D164/2** ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD), ថ្ងៃទី១៩ មិថុនា ២០០៩, កថាខណ្ឌទី១៤ ("ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនត្រឹមតែផ្តល់សមត្ថកិច្ចលើសំណុំរឿងទៅឱ្យសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបញ្ចប់សិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញា លើការស៊ើបសួរលើអង្គហេតុដូចគ្នានេះ")។

[29] វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង។

[30] **A110/II** ចម្លើយតបរបស់ កសចស ទៅនឹងលិខិតរបស់មេធាវី នួន ជា ស្តីពីការដឹកនាំកិច្ចស៊ើបសួរ, ១០ មករា ២០០៨, កថាខណ្ឌទី៣។

[31] វិធាន៩៣(១) នៃវិធានផ្ទៃក្នុង ចែងថា: "ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា។ សាលក្រមមុនអង្គសេចក្តីនេះ ត្រូវកំណត់បង្ហាញចៅក្រមមួយរូប ឬច្រើនរូប ដែលត្រូវជាអ្នកដឹកនាំការស៊ើបសួរថ្មីនេះ"។

អះអាងផងដែរថា "ក្របខណ្ឌច្បាប់ អ.វ.ត.ក ច្រានចោលជាមុន នូវកិច្ចស៊ើបសួរដែលបានធ្វើឡើងដោយភាគី"[32]។

21. វិធានមិនត្រឹមតែបែងចែកនូវមុខងារស៊ើបសួរផ្តាច់មុខរបស់ អ.វ.ត.ក ទៅឲ្យសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងហាមឃាត់ភាគីពីការជ្រៀតជ្រែកទៅលើសាក្សីផងដែរ។ វិធាន ៣៥(១)(ឃ) ចែងអំពីទណ្ឌកម្មប្រឆាំងនឹងបុគ្គលណាដែល "ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬលើសាក្សីសក្តានុពល ដែលអាចផ្តល់ភ័ស្តុតាងក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ" ហើយវិធាន៣៨ ចែងអំពីទណ្ឌកម្មសម្រាប់មេធាវីណាម្នាក់ដែលការប្រព្រឹត្តរបស់ខ្លួន ធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ឬមានតម្លៃស្មើនឹងការរំលោភបំពានដំណើរការ។ ក្នុងចម្លើយតបទៅនឹងសំណើមួយធ្វើឡើងដោយមេធាវីការពារក្តី នួន ជា សុំដឹកនាំធ្វើសម្ភាសន៍សាក្សីដោយខ្លួនឯង សចស បានព្រមានកាលពីលើកមុនរួចហើយដល់មេធាវីរូបនោះ អំពីបទប្បញ្ញត្តិនៃវិធាន៣៥ និង ៣៨ ព្រមទាំងច្បាប់កម្ពុជាផងដែរ ដោយបានចាត់ទុកថា វាជាបទមជ្ឈិម ចំពោះ "ការគាបសង្កត់លើសាក្សីណាម្នាក់ ក្នុងនីតិវិធីតុលាការ"[33]។

22. អាស្រ័យហេតុនេះ គេពិតជាមានការរំជើបរំជួលដែលមេធាវីការពារក្តី អៀង សារី បានទៅនិយាយដោយខ្លួនឯង ដោយផ្ទាល់ទៅអ្នកបកប្រែផ្ទាល់មាត់ ដែលខ្លួនចង់ឲ្យកោះហៅមកធ្វើជាសាក្សី[34]។ ក្នុងញត្តិស្នើសុំមួយដែលពួកគេជំទាស់អំពីកំហុសខាងនីតិវិធីដោយ កសចស យ៉ាងសង្កៀរត្រចៀក មេធាវីការពារក្តី អៀង សារី បានរំលោភដោយចេតនាលើវិធានស្នូលមួយក្នុងចំណោមវិធានស្នូលនានារបស់តុលាការនេះ ដែលពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយសាក្សីម្នាក់ដែលគេបានស្នើឡើង។ ការធ្វើទំនាក់ទំនង និងការប៉ុនប៉ងដោយខុសច្បាប់របស់មេធាវីការពារក្តីដើម្បីទទួលបាន ឬដាក់ឥទ្ធិពលទៅលើសក្ខីកម្មរបស់បុគ្គលរូបនេះ គឺជាហេតុផលមួយផ្សេងទៀតសម្រាប់ការបដិសេធចោលសំណើរបស់មេធាវីការពារក្តី ដែលសុំឲ្យកោះហៅអ្នកបកប្រែផ្ទាល់មាត់រូបនេះ មកផ្តល់សក្ខីកម្មនៅក្នុងសវនាការជំនុំជម្រះ។

---

[32] **E211/2** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង អំពីសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី នួន ជា មកអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា, ១៣ សីហា ២០១២, កថាខណ្ឌទី២។

[33] **A110/II** ចម្លើយតបរបស់ កសចស ទៅនឹងលិខិតរបស់មេធាវី នួន ជា ស្តីពីការដឹកនាំការស៊ើបសួរ, ១០ មករា ២០០៨, កថាខណ្ឌទី៣។

[34] **E221** សំណើសុំ, កថាខណ្ឌទី៨។

## III. សេចក្តីសន្និដ្ឋាន

23. ដោយសារមូលហេតុដូចបានថែងពីខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំនេះដែលធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី ត្រូវបានបដិសេធចោល ហើយមេធាវីគួរតែទទួលការព្រមាន មិនឲ្យប្រាស្រ័យទាក់ទងផ្ទាល់ជាមួយសាក្សីដែលបានស្នើសុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |